អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

## សេចក្តីប្រកាសព័ត៌មានរបស់ ជំនួយអង្គការសហប្រជាជាតិសំរាប់ការកាត់សេចក្តីខ្មែរក្រហម
## ថ្ងៃទី ០៣ ខែមេសា ឆ្នាំ២០០៧

### ចៅក្រមអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និយាយថា
### អង្គប្រជុំពេញអង្គ ក្នុងខែមេសា មិនអាចធ្វើទៅបាន

ចៅក្រមអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានាថ្ងៃនេះ បានផ្ញើអនុស្សារណៈមួយ ជូនទៅប្រធានតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ជំរាបអំពីសេចក្តីសំរេចរបស់ខ្លួន ដោយមិនធ្វើការកោះប្រជុំអង្គប្រជុំពេញអង្គដើម្បីអនុម័តវិធានផ្ទៃក្នុងរបស់តុលាការ នៅក្នុងខែមេសា ឆ្នាំ២០០៧នេះ។

អនុស្សារណៈដែលចុះហត្ថលេខាដោយចៅក្រមបរទេសទាំងអស់នៅក្នុង អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គត់សំគាល់ថា រយៈពេល ពីរសប្តាហ៍បានកន្លងហួសផុតទៅហើយ ចាប់តាំងពីពេលដែលគណៈកម្មាធិការពិនិត្យឡើងវិញរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានចេញសេចក្តីថ្លែងមួយស្នើសុំអោយគណៈមេធាវីកម្ពុជាពិចារណាជាថ្មីគោលជំហររបស់ខ្លួនក្នុងការកំណត់តម្លៃលើមេធាវីបរទេស។ អនុស្សារណៈថ្លែងថា “ចៅក្រមអន្តរជាតិ មានការសោកស្តាយណាស់ដែលថា មកទល់នឹងពេលសរសេរអនុស្សារណៈនេះ គណៈមេធាវីនៅមិនទាន់ពិចារណាជាថ្មីនូវគោលជំហររបស់ខ្លួននៅឡើយ”។ ជាមួយនឹងបញ្ហាកំណត់តម្លៃដែលមិនទាន់ដោះស្រាយរួច បូករួមនឹងពេលវេលាមិនគ្រប់គ្រាន់សំរាប់រៀបចំកម្មវិធីរបស់ពួកគេដើម្បីលៃលកពេលសំរាប់ការរៀបចំពីមុនមករបស់ពួកគេ អង្គប្រជុំពេញអង្គនាថ្ងៃទី ៣០ ខែមេសា គឺមិនមានលទ្ធភាពធ្វើទៅបានសំរាប់ចៅក្រមអន្តរជាតិ។

ចៅក្រមអន្តរជាតិជឿជាក់ថា សំណើកំណត់តម្លៃរបស់គណៈមេធាវីកម្ពុជា សំរាប់ឆ្នាំដំបូង ចំនួន ៤៩០០ ដុល្លារ នឹងបង្កើតអោយមានតម្លៃទទួលសិទ្ធិចូលមួយដ៏ថ្លៃបំផុត ហើយដែលមិនស៊ីសង្វាក់គ្នាជាមួយការអនុវត្តដែលទទួលយកបានកំរិតអន្តរជាតិ។ តម្លៃដែលបានស្នើឡើង នេះ នឹងមានការកំរិតដ៏ធ្ងន់ធ្ងរបំផុតទៅលើចំនួនមេធាវីបរទេស ដែលមានលទ្ធភាពមកតំណាងនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នឹងអាចផ្តល់លទ្ធភាពដល់ជនជាប់ចោទធ្វើការតវ៉ាថា ពួកគេមិនបានទទួលសិទ្ធិជ្រើសរើសមេធាវីរបស់ខ្លួន ដែលផ្ទុយនឹងកតិកាសញ្ញាអន្តរជាតិស្តីអំពី សិទ្ធិស៊ីវិលនិងសិទ្ធិនយោបាយ។ លើសពីនេះទៀត តម្លៃបែបនេះនឹងមិនដាក់បញ្ចូលមេធាវីជាច្រើនរូបទៀត ដែលស្ម័គ្រចិត្តតំណាងជនរងគ្រោះដោយមិនយកថ្លៃ

National Road 4, Chaom Chau Commune, Dangkao District
P.O.BOX 71, Phnom Penh, Cambodia.
Phone: 023 219814 Fax: 023 219841

ដោយសារតែពួកគេនឹងខាតបង់ប្រាក់ពីក្នុងហោប៉ៅរបស់ខ្លួនយ៉ាងច្រើន ក្នុងការផ្តល់សេវាដោយឥតគិតថ្លៃរបស់ខ្លួន។

ចៅក្រមអន្តរជាតិយល់ដឹងថា កំពុងតែមានការពិភាក្សាគ្នាជាបន្តរវាងគណៈមេធាវីកម្ពុជានិង ផ្នែកគាំពារការពារក្តីនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ហើយបង្ហាញនូវសេចក្តីសង្ឃឹមថា ការពិភាក្សាទាំងនេះនឹងឈានទៅរកដំណោះស្រាយមួយដែលអាចទទួលយកបាន។ ជាលទ្ធផល ពួកគេនឹងអាចអនុញ្ញាតុទុកពេលវេលាខ្លីមួយ ដើម្បីថ្លឹងថ្លែងថាតើពួកគេនឹងអាចមានគោលជំហរដើម្បីកោះប្រជុំអង្គប្រជុំពេញអង្គ នៅពេលក្រោយទៀតបានឬទេ។

ទោះជាយ៉ាងណាក្តី ចៅក្រមអន្តរជាតិសំគាល់ឃើញថា បង្អួចនៃឱកាសពេលវេលាកំពុងតែបិទយ៉ាងលឿន ហើយពួកគេមិនអាចអនុញ្ញាតអោយមានការពន្យាពេលមិនចេះចប់បានទេ។

ចៅក្រមអន្តរជាតិនឹងធ្វើការពិនិត្យស្ថានភាពជាថ្មីឡើងវិញ និងសំណើរនានាបើមានពីគណៈមេធាវីកម្ពុជាក្នុងសប្តាហ៍ចុងក្រោយនៃខែមេសា ឆ្នាំ២០០៧។ ប្រសិនបើដល់ពេលនោះ មិនមានការឈានទៅមុខទេ ពួកគេនឹងស្នើអោយមានការរៀបចំដំណើរការទាំងមូលនៃការចូលរួមរបស់មេធាវីបរទេស ចាប់តាំងពីការចុះឈ្មោះរហូតដល់ការដាក់ពិន័យ ដោយមិនចាំបាច់មានជំនួយពីគណៈមេធាវីកម្ពុជា ដែលចំណុចនេះស៊ីសង្វាក់គ្នាជាមួយការអនុវត្តដែលត្រូវបានគេបង្កើតឡើងនៅក្នុងតុលាការអន្តរជាតិនិងតុលាការកូនកាត់នានា។

ចៅក្រមអន្តរជាតិបានបញ្ចប់អនុស្សារណៈរបស់ខ្លួន ដោយមានការប្តេជ្ញាចិត្តដល់ “ការកាត់សេចក្តីបានឆាប់រហ័ស មានតម្លាភាព និងយុត្តិធម៌ ដែលប្រជាជនកម្ពុជាបានទន្ទឹងរង់ចាំអស់រយៈពេល ២៥ឆ្នាំមកហើយ”។

National Road 4, Chaom Chau Commune, Dangkao District
P.O.BOX 71, Phnom Penh, Cambodia.
Phone: 023 219814 Fax: 023 219841